[១៦០] ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ គឺ ខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ (ជាបច្ច័យ) នៃខន្ធ ៣ . . . ក្នុងខណៈនៃបដិសន្ធិ . . . ។ ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបច្ឆាជាត ។ បេយ្យាលៈ ។ ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុផង ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ដោយអត្ថិប្បច្ច័យ គឺ ខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យ នៃខន្ធ៣ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ

បដិសន្ធិក្ខណេ . . . ។ នហេតុ អហេតុកោ ធម្មោ នហេតុអហេតុកស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ ។ សហជាតោ នហេតុ អហេតុកោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អត្ថិប្បច្ចយេន បច្ចយោ យាវ អសញ្ញសត្តា ។ បុរេជាតំ ចក្ខុំ . . . វត្ថុំ អនិច្ចតោ . . . ទោមនស្សំ ឧប្បជ្ជតិ រូបាយតនំ ចក្ខុវិញ្ញាណស្ស ផោដ្ឋព្វាយតនំ កាយវិញ្ញាណស្ស ចក្ខាយតនំ . . . កាយាយតនំ កាយវិញ្ញាណស្ស វត្ថុ នហេតុអហេតុកានំ ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ។ បច្ឆាជាតា នហេតូ អហេតុកា ខន្ធា បុរេជាតស្ស ឥមស្ស កាយស្ស កពឡីការោ អាហារោ ឥមស្ស កាយស្ស រូបជីវិតិន្ទ្រិយំ កដត្តារូបានំ អត្ថិប្បច្ចយេន បច្ចយោ ។ នហេតុ អហេតុកោ ធម្មោ នហេតុសហេតុកស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ ។ សហជាតំ បដិសន្ធិក្ខណេ វត្ថុ នហេតុសហេតុកានំ ខន្ធានំ អត្ថិប្បច្ចយេន បច្ចយោ ។

ក្នុងខណៈនៃបដិសន្ធិ . . . ។ ធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បុរេជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺ ខន្ធ ១ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យ នៃខន្ធ ៣ ផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអត្ថិប្បច្ច័យ រហូតដល់ពួកអសញ្ញសត្វ (ក៏ដូចគ្នាដែរ) ។ បុរេជាត គឺ នូវចក្ខុ . . . នូវវត្ថុ ថាមិនទៀង . . . ទោមនស្ស កើតឡើង រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ ចក្ខាយតនៈ . . . កាយាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យ នៃពួកខន្ធ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ ។ ឯបច្ឆាជាត គឺ ពួកខន្ធ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ (ជាបច្ច័យ) នៃកាយនេះ ដែលកើតមុន កពឡីការាហារ (ជាបច្ច័យ) នៃកាយនេះ រូបជីវិតិន្ទ្រិយ ជាបច្ច័យ នៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។ ធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត ។ សហជាត គឺ ក្នុងខណៈនៃបដិសន្ធិ វត្ថុ ជាបច្ច័យ នៃពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ ។

១៤៧



បុរេជាតំ . . . វត្ថុំ អនិច្ចតោ . . . ទោមនស្សំ ឧប្បជ្ជតិ កុសលាកុសលេ និរុទ្ធេ នហេតុ សហេតុកោ វិបាកោ តទារម្មណតា ឧប្បជ្ជតិ ។ នហេតុ សហេតុកោ ច នហេតុ អហេតុកោ ច ធម្មា នហេតុសហេតុកស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ សហជាតំ បុរេជាតំ ។ សហជាតោ នហេតុ សហេតុកោ ឯកោ ខន្ធោ ច វត្ថុ ច តិណ្ណន្នំ ខន្ធានំ . . . បដិសន្ធិក្ខណេ នហេតុ សហេតុកោ ឯកោ ខន្ធោ ច វត្ថុ ច តិណ្ណន្នំ . . . ។ នហេតុ សហេតុកោ ច នហេតុ អហេតុកោ ច ធម្មា នហេតុអហេតុកស្ស ធម្មស្ស អត្ថិប្បច្ចយេន បច្ចយោ សហជាតំ បច្ឆាជាតំ អាហារំ ឥន្ទ្រិយំ ។ សហជាតា នហេតូ សហេតុកា ខន្ធា ច មហាភូតា ច ចិត្តសមុដ្ឋានានំ រូបានំ អត្ថិប្បច្ចយេន បច្ចយោ ។ បច្ឆាជាតា នហេតូ សហេតុកា ខន្ធា ច កពឡីការោ អាហារោ ច ឥមស្ស កាយស្ស អត្ថិប្បច្ចយេន បច្ចយោ

ឯបុរេជាត គឺ . . . នូវវត្ថុ ថាមិនទៀង . . . ទោមនស្ស កើតឡើង កាលកុសលនិងអកុសល រលត់ហើយ វិបាក ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ កើតឡើង ព្រោះកុសលនិងអកុសលនោះ ជាអារម្មណ៍ ។ ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក្តី ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់សហជាត និងបុរេជាត ។ សហជាត គឺ ខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី វត្ថុក្តី (ជាបច្ច័យ) នៃខន្ធ ៣ . . . ក្នុងខណៈនៃបដិសន្ធិ ខន្ធ ១ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី វត្ថុក្តី (ជាបច្ច័យ) នៃខន្ធ ៣ . . . ។ ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក្តី ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអត្ថិប្បច្ច័យ បានដល់សហជាត បច្ឆាជាត អាហារ និងឥន្ទ្រិយ ។ សហជាត គឺ ពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី ពួកមហាភូតក្តី ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ដោយអត្ថិប្បច្ច័យ ។ បច្ឆាជាត គឺ ពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី កពឡីការាហារក្តី ជាបច្ច័យ នៃកាយនេះ ដោយអត្ថិប្បច្ច័យ

បច្ឆាជាតា នហេតុ សហេតុកា ខន្ធា ច រូបជីវិតិន្ទ្រិ-
យញ្ច កដត្តារូបានំ អត្ថិប្បច្ចយេន បច្ចយោ ។

[១៦១] អារម្មណេ ចត្តារិ អធិបតិយា ចត្តារិ អនន្តរេ ចត្តារិ សមនន្តរេ ចត្តារិ សហជាតេ សត្ត អញ្ញមញ្ញេ ឆ និស្សយេ សត្ត ឧបនិស្សយេ ចត្តារិ បុរេជាតេ ទ្វេ បច្ឆាជាតេ ទ្វេ អាសេវនេ ទ្វេ កម្មេ ចត្តារិ វិបាកេ ចត្តារិ អាហារេ ចត្តារិ ឥន្ទ្រិយេ ចត្តារិ ឈានេ ចត្តារិ មគ្គេ តីណិ សម្បយុត្តេ ទ្វេ វិប្បយុត្តេ តីណិ អត្ថិយា សត្ត នត្ថិយា ចត្តារិ វិគតេ ចត្តារិ អវិគតេ សត្ត ។ ឯវំ គណេតព្វំ ។

អនុលោមំ និដ្ឋិតំ ។

[១៦២] នហេតុ សហេតុកោ ធម្មោ នហេតុសហេតុកស្ស ធម្មស្ស អារម្មណប្បច្ច-
យេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ

បច្ឆាជាត គឺ ពួកខន្ធ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី រូបជីវិតិន្ទ្រិយក្តី ជាបច្ច័យ នៃពួកកដត្តារូប ដោយអត្ថិប្បច្ច័យ ។

[១៦១] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងសហជាតប្បច្ច័យ មានវារៈ ៧ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៧ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ២ ក្នុងបច្ឆាជាតប្បច្ច័យ មានវារៈ ២ ក្នុងអាសេវនប្បច្ច័យ មានវារៈ ២ ក្នុងកម្មប្បច្ច័យ មានវារៈ ៤ ក្នុងវិបាកប្បច្ច័យ មានវារៈ ៤ ក្នុងអាហារប្បច្ច័យ មានវារៈ ៤ ក្នុងឥន្ទ្រិយប្បច្ច័យ មានវារៈ ៤ ក្នុងឈានប្បច្ច័យ មានវារៈ ៤ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ២ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនត្ថិប្បច្ច័យ មានវារៈ ៤ ក្នុងវិគតប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោម ។

[១៦២] ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ

១៤៩



ឧបនិស្សយប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។ នហេតុ សហេតុកោ ធម្មោ នហេតុអហេតុកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។ នហេតុ សហេតុកោ ធម្មោ នហេតុសហេតុកស្ស ច នហេតុអហេតុកស្ស ច ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។ នហេតុ អហេតុកោ ធម្មោ នហេតុអហេតុកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សហជាតប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ។ នហេតុ អហេតុកោ ធម្មោ នហេតុសហេតុកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ ។ នហេតុ សហេតុកោ ច នហេតុ អហេតុកោ ច ធម្មា នហេតុសហេតុកស្ស ធម្មស្ស

ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។ ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។ ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ ជាបច្ច័យ នៃធម៌ ដែល មិនមែនជាហេតុ តែប្រកបដោយហេតុផង ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុផង ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយ កម្មប្បច្ច័យ ។ ធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ។ ធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកប ដោយហេតុ ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយ ហេតុ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជា បច្ច័យ ដោយបុរេជាតប្បច្ច័យ ។ ធម៌ ដែលមិនមែនជាហេតុ តែ ប្រកបដោយហេតុក្តី ធម៌ ដែលមិនមែនជាហេតុ ទាំងមិនប្រកបដោយ ហេតុក្តី (ជាបច្ច័យ) នៃធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុ

សហជាតប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ ។ នហេតុ សហេតុកោ ច នហេតុ អហេតុកោ ច ធម្មា នហេតុអហេតុកស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ច-យេន បច្ចយោ ។

[១៦៣] នហេតុយា សត្ត នអារម្មណេ សត្ត ។ សង្ខិត្តំ ។ សព្វត្ថ សត្ត នសហជាតេ ឆ នអញ្ញមញ្ញេ ឆ ននិស្សយេ ឆ សព្វត្ថ សត្ត នសម្បយុត្តេ ឆ នវិប្បយុត្តេ បញ្ច នោអត្ថិយា បញ្ច នោនត្ថិយា សត្ត នោវិគតេ សត្ត នោអវិគតេ បញ្ច ។ ឯវំ គណេតព្វំ ។

បច្ចនីយំ និដ្ឋិតំ ។

[១៦៤] អារម្មណប្បច្ចយា នអធិបតិយា ចត្តារិ . . . នអនន្តរេ ចត្តារិ សព្វត្ថ ចត្តារិ នោនត្ថិយា ចត្តារិ

ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ។ ធម៌ ដែលមិនមែនជាហេតុ តែប្រកបដោយហេតុក្តី ធម៌ ដែលមិនមែនជាហេតុទាំងមិនប្រកបដោយហេតុក្តី ជាបច្ច័យ នៃធម៌ ដែលមិនមែនជាហេតុទាំងមិនប្រកបដោយហេតុ ដោយសហជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ។

[១៦៣] ក្នុងនហេតុប្បច្ច័យ មានវារៈ ៧ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៧ ។ សេចក្តីបំប្រួញ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៧ ក្នុងនសហជាតប្បច្ច័យ មានវារៈ ៦ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៦ ក្នុងននិស្សយប្បច្ច័យ មានវារៈ ៦ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៧ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៦ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៥ ក្នុងនោអត្ថិប្បច្ច័យ មានវារៈ ៥ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៧ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៧ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៥ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយៈ ។

[១៦៤] ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៤ ព្រោះអារម្មណប្បច្ច័យ . . . ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៤ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៤

ដោវិកតេ ចត្តារិ ដោអវិកតេ ចត្តារិ ។ ឯវំ គណេតព្វំ ។

អនុលោមប្បច្ចនីយំ និដ្ឋិតំ ។

[១៦៥] ជហេតុប្បច្ចយា អារម្មណេ ចត្តារិ . . . អធិបតិយា ចត្តារិ អវិគតេ សត្ត ។ ឯវំ គណេតព្វំ ។

បច្ចនីយានុលោមំ និដ្ឋិតំ ។

នហេតុសហេតុកទុកំ និដ្ឋិតំ ។

# សប្បច្ចយទុកំ

## បដិច្ចវារោ

[១៦៦] សប្បច្ចយំ ធម្មំ បដិច្ច សប្បច្ចយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សប្បច្ចយំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . . បដិសន្ធិក្ខណេ ខន្ធេ បដិច្ច វត្ថុ វត្ថុំ បដិច្ច ខន្ធា ឯកំ មហាភូតំ . . . មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ។

ក្នុងនោវិគតប្បច្ច័យ មានវារៈ ៤ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ៤ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោមប្បច្ចនីយៈ ។

[១៦៥] ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ព្រោះនហេតុប្បច្ច័យ . . . ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយានុលោម ។

ចប់ នហេតុសហេតុកទុកៈ ។

# សប្បច្ចយទុកៈ

## បដិច្ចវារៈ

[១៦៦] ធម៌ ដែលប្រកបដោយបច្ច័យ អាស្រ័យ នូវធម៌ ដែលប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវខន្ធ ១ ដែលប្រកបដោយបច្ច័យ នូវខន្ធ ២ . . . វត្ថុ អាស្រ័យ នូវពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធ អាស្រ័យ នូវវត្ថុ មហាភូត ១ . . . ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យ នូវពួកមហាភូត ។

[១៦៧] សប្បច្ចយំ ធម្មំ បដិច្ច សប្បច្ចយោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា ។ សង្ខិត្តំ ។ អវិគតប្បច្ចយា ។

[១៦៨] ហេតុយា ឯកំ អារម្មណេ ឯកំ ។ សង្ខិត្តំ ។ អវិគតេ ឯកំ ។

អនុលោមំ និដ្ឋិតំ ។

[១៦៩] សប្បច្ចយំ ធម្មំ បដិច្ច សប្បច្ចយោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ សប្បច្ចយំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . . អហេតុកប្បដិសន្ធិក្ខណេ . . . យាវ អសញ្ញសត្តា វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។ សង្ខិត្តំ ។

[១៧០] នហេតុយា ឯកំ នអារម្មណេ ឯកំ នអធិបតិយា ឯកំ នោវិគតេ ឯកំ ។

បច្ចនីយំ និដ្ឋិតំ ។

[១៦៧] ធម៌ ដែលប្រកបដោយបច្ច័យ អាស្រ័យ នូវធម៌ ដែលប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ព្រោះអវិគតប្បច្ច័យ ។

[១៦៨] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ។ សេចក្តីបំប្រួញ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ចប់ អនុលោម ។

[១៦៩] ធម៌ ដែលប្រកបដោយបច្ច័យ អាស្រ័យ នូវធម៌ ដែលប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវអហេតុកក្ខន្ធ ១ ដែលប្រកបដោយបច្ច័យ នូវខន្ធ ២ . . . ក្នុងខណៈនៃអហេតុកប្បដិសន្ធិ . . . ដរាបដល់ពួកអសញ្ញសត្វ មោហៈ ដែលប្រទាំដោយវិចិកិច្ឆា ប្រទាំដោយឧទ្ធច្ចៈ អាស្រ័យ នូវពួកខន្ធ ដែលប្រទាំដោយវិចិកិច្ឆា ប្រទាំដោយឧទ្ធច្ចៈ ។ សេចក្តីបំប្រួញ ។

[១៧០] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។

ចប់ បច្ចនីយៈ ។

[១៧១] ហេតុប្បច្ចយា នអារម្មណេ ឯកំ . . . នអធិបតិយា ឯកំ សង្ខិត្តំ នោវិគតេ ឯកំ ។

អនុលោមប្បច្ចនីយំ និដ្ឋិតំ ។

[១៧២] ហេតុប្បច្ចយា អារម្មណេ ឯកំ . . . អនន្តរេ ឯកំ សង្ខិត្តំ អវិគតេ ឯកំ ។

បច្ចនីយានុលោមំ និដ្ឋិតំ ។

សហជាតវារោ បដិច្ចវារសទិសោ ។

## បច្ចយវារោ

[១៧៣] សប្បច្ចយំ ធម្មំ បច្ចយា សប្បច្ចយោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សប្បច្ចយំ ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ បដិសន្ធិក្ខណេ ខន្ធេ បច្ចយា វត្ថុ វត្ថុំ បច្ចយា ខន្ធា ឯកំ មហាភូតំ . . . វត្ថុំ បច្ចយា សប្បច្ចយា ខន្ធា ។

[១៧៤] សប្បច្ចយំ ធម្មំ បច្ចយា សប្បច្ចយោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា ។ សង្ខិត្តំ ។

សប្បច្ចយទុកៈ បច្ចយវារៈ

*[១៧១] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ . . . ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ សេចក្ដីបំប្រួញ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។*

ចប់ អនុលោមប្បច្ចនីយៈ ។

*[១៧២] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ . . . ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ សេចក្ដីបំប្រួញ . . . ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។*

ចប់ បច្ចនីយានុលោម ។

*សហជាតវារៈ ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។*

# បច្ចយវារៈ

*[១៧៣] ធម៌ ដែលប្រកបដោយបច្ច័យ ពឹងផ្អែក នឹងធម៌ ដែលប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្ដី ចិត្តសមុដ្ឋានរូបក្ដី ពឹងផ្អែក នឹងខន្ធ ១ ដែលប្រកបដោយបច្ច័យ វត្ថុ ពឹងផ្អែក នឹងពួកខន្ធ ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធ ពឹងផ្អែក នឹងវត្ថុ មហាភូត ១ . . . ពួកខន្ធ ដែលប្រកបដោយបច្ច័យ ពឹងផ្អែក នឹងវត្ថុ ។*

*[១៧៤] ធម៌ ដែលប្រកបដោយបច្ច័យ ពឹងផ្អែក នឹងធម៌ ដែលប្រកបដោយបច្ច័យ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ សេចក្ដីបំប្រួញ ។*

ឯវំ បច្ចយភាគេបិ និស្សយភាគេបិ សំសដ្ឋភាគេបិ សម្បយុត្តភាគេបិ វិត្ថារេតព្វា ។ សព្វត្ថ ឯកាយេវ បញ្ហា ។

# បញ្ហាវារោ

[១៧៥] សប្បច្ចយោ ធម្មោ សប្បច្ចយស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ សប្បច្ចយា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ បដិសន្ធិក្ខណេ . . . ។

[១៧៦] សប្បច្ចយោ ធម្មោ សប្បច្ចយស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ ទត្វា សីលំ សមាទិយិត្វា ឧបោសថកម្មំ . . . តំ បច្ចវេក្ខតិ បុព្វេ សុចិណ្ណានិ បច្ចវេក្ខតិ ឈានា វុដ្ឋហិត្វា ឈានំ បច្ចវេក្ខតិ អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ បច្ចវេក្ខន្តិ ផលំ បច្ចវេក្ខន្តិ បហីនេ កិលេសេ . . . វិក្ខម្ភិតេ កិលេសេ បច្ចវេក្ខន្តិ បុព្វេ សមុទាចិណ្ណេ កិលេសេ ជានន្តិ ចក្ខុំ . . . វត្ថុំ . . . សប្បច្ចយេ ខន្ធេ អនិច្ចតោ . . . ទោមនស្សំ ឧប្បជ្ជតិ ទិព្វេន ចក្ខុនា រូបំ បស្សតិ

បច្ចយវារៈក្តី និស្សយវារៈក្តី សំសដ្ឋវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនេះចុះ ។ ក្នុងវារៈទាំងអស់ មានប្រស្នាតែមួយគត់ ។

## បញ្ហាវារៈ

[១៧៥] ធម៌ ដែលប្រកបដោយបច្ច័យ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយបច្ច័យ ដោយហេតុប្បច្ច័យ គឺ ពួកហេតុ ដែលប្រកបដោយបច្ច័យ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ ... ។

[១៧៦] ធម៌ ដែលប្រកបដោយបច្ច័យ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ គឺ បុគ្គល ឲ្យទាន សមាទានសីល ឧបោសថកម្ម . . . ពិចារណា នូវកុសលនោះ ពិចារណា នូវពួកកុសល ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ហើយពិចារណា នូវឈាន ពួកព្រះអរិយៈ ចេញអំពីមគ្គ ហើយពិចារណា នូវមគ្គ ពិចារណា នូវផល នូវពួកកិលេស ដែលលះបង់ហើយ . . . ពិចារណា នូវពួកកិលេស ដែលសង្កត់សង្កិនហើយ ដឹង នូវពួកកិលេស ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន នូវចក្ខុ . . . នូវវត្ថុ . . . នូវពួកខន្ធ ដែលប្រកបដោយបច្ច័យ ថាមិនទៀង ... ទោមនស្ស កើតឡើង បុគ្គល ឃើញ នូវរូប ដោយទិព្វចក្ខុ

និព្វាយ សោតធាតុយា សទ្ទំ សុណាតិ ចេតោបរិយញ្ញាណេន សប្បច្ចយចិត្តសមង្គិស្ស ចិត្តំ ជានាតិ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនស្ស រូបាយតនំ ចក្ខុវិញ្ញាណស្ស ផោដ្ឋព្វាយតនំ កាយវិញ្ញាណស្ស សប្បច្ចយា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មុបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។ អប្បច្ចយោ ធម្មោ សប្បច្ចយស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ អរិយា និព្វានំ បច្ចវេក្ខន្តិ និព្វានំ គោត្រភុស្ស វោទានស្ស មគ្គស្ស ផលស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។

[១៧៧] សប្បច្ចយោ ធម្មោ សប្បច្ចយស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។ អារម្មណាធិបតិ ទានំ ទត្វា សីលំ . . . ឧបោសថកម្មំ . . . តំ គរុំ កត្វា បច្ចវេក្ខតិ បុព្វេ . . . ឈានា . . . អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ គរុំ កត្វា

ឮ នូវសំឡេង ដោយទិព្វសោតធាតុ ដឹង នូវចិត្ត របស់បុគ្គល ដែលប្រកបដោយចិត្តដែលប្រកបដោយបច្ច័យ ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ វិញ្ញាណញ្ចាយតនៈ និងអាកិញ្ចញ្ញាយតនៈ (ជាបច្ច័យ) នៃនេវសញ្ញានាសញ្ញាយតនៈ រូបាយតនៈ (ជាបច្ច័យ) នៃចក្ខុ-វិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយវិញ្ញាណ ពួកខន្ធ ដែលប្រកបដោយបច្ច័យ ជាបច្ច័យ នៃការពិចារណា នូវឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ និង អនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ ធម៌ ដែលមិនមែនជាបច្ច័យ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈ ពិចារណា នូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យ នៃការពិចារណា នូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ ។

[១៧៧] ធម៌ ដែលប្រកបដោយបច្ច័យ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណា-ធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គល ឲ្យទាន សីល . . . ឧបោសថកម្ម . . . ធ្វើ នូវកុសលនោះ ឲ្យជាទីគោរព ហើយពិចារណា ក្នុងកាលមុន . . . អំពីឈាន . . . ពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើ នូវមគ្គ ឲ្យជាទីគោរព

បច្ចវេក្ខន្តិ ផលំ គរុំ . . . ចក្ខុំ . . . វត្ថុំ . . . សប្បច្ចយេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។ សហជាតាធិបតិ សប្បច្ចយាធិបតិ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។ អប្បច្ចយោ ធម្មោ សប្បច្ចយស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ អរិយា និព្វានំ គរុំ កត្វា បច្ចវេក្ខន្តិ និព្វានំ គោត្រភុស្ស វោទានស្ស មគ្គស្ស ផលស្ស អធិបតិប្បច្ចយេន បច្ចយោ ។

[១៧៨] សប្បច្ចយោ ធម្មោ សប្បច្ចយស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ សង្ខិត្តំ ។ ឧបនិស្សយប្បច្ចយេន បច្ចយោ ទ្វេ បញ្ហា ឧបនិស្សយមូលំ ។ បុរេជាតប្បច្ចយេន បច្ចយោ ។ សង្ខិត្តំ ។ អវិគតប្បច្ចយេន បច្ចយោ សព្វត្ថ ឯកាយេវ បញ្ហា ។

[១៧៩] ហេតុយា ឯកំ អារម្មណេ ទ្វេ អធិបតិយា ទ្វេ អនន្តរេ ឯកំ សមនន្តរេ ឯកំ សហជាតេ ឯកំ

ហើយពិចារណា នូវផល ឲ្យជាទីគោរព . . . នូវចក្ខុ . . .  នូវវត្ថុ . . . បុគ្គល ធ្វើ នូវពួកខន្ធ ដែលប្រកបដោយបច្ច័យ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ កើតឡើង ព្រោះធ្វើ នូវខន្ធនោះ ឲ្យជាទីគោរព ទិដ្ឋិ កើតឡើង ។ ឯសហជាតាធិបតិ គឺ អធិបតិធម៌ ដែលប្រកបដោយបច្ច័យ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូបផង ដោយអធិបតិប្បច្ច័យ ។ ធម៌ ដែលមិនមែនជាបច្ច័យ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអធិបតិប្បច្ច័យ បាន ដល់អារម្មណាធិបតិ គឺ ពួកព្រះអរិយៈ ធ្វើ នូវព្រះនិព្វាន ឲ្យជាទីគោរព ហើយពិចារណា ព្រះនិព្វាន ជាបច្ច័យ នៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្បច្ច័យ ។

[១៧៨] ធម៌ ដែលប្រកបដោយបច្ច័យ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអនន្តរប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ គឺ មានបញ្ហា ២ ជាមូល នៃឧបនិស្សយប្បច្ច័យ ។ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ។ សេចក្តីបំប្រួញ ។ ជាបច្ច័យ ដោយអវិគតប្បច្ច័យ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានបញ្ហាមួយ ។

[១៧៩] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ១

១៨៧



អញ្ញមញ្ញេ ឯកំ និស្សយេ ឯកំ ឧបនិស្សយេ ទ្វេ បុរេជាតេ ឯកំ សព្វត្ថ ឯកំ អវិគតេ ឯកំ ។ ឯវំ គណេតព្វំ ។

អនុលោមំ និដ្ឋិតំ ។

[១៨០] សប្បច្ចយោ ធម្មោ សប្បច្ចយស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ បុរេជាតប្បច្ចយេន បច្ចយោ បច្ឆាជាតប្បច្ចយេន បច្ចយោ កម្មប្បច្ចយេន បច្ចយោ ។ អប្បច្ចយោ ធម្មោ សប្បច្ចយស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

[១៨១] នហេតុយា ទ្វេ នអារម្មណេ ឯកំ នអធិបតិយា ទ្វេ នអនន្តរេ ទ្វេ នសមនន្តរេ ទ្វេ ។ សង្ខិត្តំ ។ នឧបនិស្សយេ ទ្វេ នបុរេជាតេ ទ្វេ ។ សង្ខិត្តំ ។ នោវិគតេ ទ្វេ នោអវិគតេ ទ្វេ ។ ឯវំ គណេតព្វំ ។

បច្ចនីយំ និដ្ឋិតំ ។

ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោម ។

[១៨០] ធម៌ ដែលប្រកបដោយបច្ច័យ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ជាបច្ច័យ ដោយបុរេជាតប្បច្ច័យ ជាបច្ច័យ ដោយបច្ឆាជាតប្បច្ច័យ ជាបច្ច័យ ដោយកម្មប្បច្ច័យ ។ ធម៌ ដែលមិនមែនជាបច្ច័យ ជាបច្ច័យ នៃធម៌ ដែលប្រកបដោយបច្ច័យ ដោយអារម្មណប្បច្ច័យ ជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យ ។

[១៨១] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ២ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ២ ។ សេចក្តីបំប្រួញ ។ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ២ ។ សេចក្តីបំប្រួញ ។ ក្នុងនោវិគតប្បច្ច័យ មានវារៈ ២ ក្នុងនោអវិគតប្បច្ច័យ មានវារៈ ២ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយៈ ។

[១៨២] ហេតុប្បច្ចយា នអារម្មណេ ឯកំ . . . នអធិបតិយា ឯកំ នអនន្តរេ ឯកំ នសមនន្តរេ ឯកំ នអញ្ញមញ្ញេ ឯកំ នឧបនិស្សយេ ឯកំ សង្ខិត្តំ . . . នសម្បយុត្តេ ឯកំ នវិប្បយុត្តេ ឯកំ នោនត្ថិយា ឯកំ នោវិគតេ ឯកំ ។ ឯវំ គណេតព្វំ ។

អនុលោមបច្ចនីយំ និដ្ឋិតំ ។

[១៨៣] នហេតុប្បច្ចយា អារម្មណេ ទ្វេ . . . អធិបតិយា ទ្វេ អនន្តរេ ឯកំ សង្ខិត្តំ . . . ឧបនិស្សយេ ទ្វេ បុរេជាតេ ឯកំ សង្ខិត្តំ . . . អវិគតេ ឯកំ ។ ឯវំ គណេតព្វំ ។

បច្ចនីយានុលោមំ និដ្ឋិតំ ។

សប្បច្ចយទុកំ និដ្ឋិតំ ។

[១៨២] ក្នុងនអារម្មណាប្បច្ច័យ មានវារៈ ១ ព្រោះហេតុប្បច្ច័យ . . . ក្នុងនអធិបតិប្បច្ច័យ មានវារៈ ១ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ១ សេចក្ដីបំប្រួញ . . . ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងនោវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិតគប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោមប្បច្ចនីយៈ ។

[១៨៣] ក្នុងអារម្មណាប្បច្ច័យ មានវារៈ ២ ព្រោះនហេតុប្បច្ច័យ . . . ក្នុងអធិបតិប្បច្ច័យ មានវារៈ ២ ក្នុអនន្តរប្បច្ច័យ មានវារៈ ១ សេចក្ដីបំប្រួញ . . . ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ សេចក្ដីបំប្រួញ . . . ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ បច្ចនីយានុលោម ។

ចប់ សប្បច្ចយទុកៈ ។

# សង្ខតទុកំ

# បដិច្ចវារោ

[១៨៤] សង្ខតំ ធម្មំ បដិច្ច សង្ខតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សង្ខតំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ចិត្តសមុដ្ឋានញ្ច រូបំ បដិសន្ធិក្ខណេ ខន្ធេ បដិច្ច វត្ថុ វត្ថុំ បដិច្ច ខន្ធា ឯកំ មហាភូតំ . . . មហាភូតេ បដិច្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ។ ឥមំ ទុកំ យថា សប្បច្ចយទុកំ ឯវំ កាតព្វំ[១] និន្នានាករណំ ។

សង្ខតទុកំ និដ្ឋិតំ ។

# សនិទស្សនទុកំ

# បដិច្ចវារោ

[១៨៥] អនិទស្សនំ ធម្មំ បដិច្ច អនិទស្សនោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនិទស្សនំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា អនិទស្សនំ ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . . បដិសន្ធិក្ខណេ អនិទស្សនំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា អនិទស្សនំ កដត្តា ច រូបំ

---

១ ម. គណេតព្វន្តិ ទិស្សតិ ។

# សង្ខតទុកៈ

## បដិច្ចវារៈ

[១៨៤] *សង្ខតធម៌* (ធម៌ ដែលមានបច្ច័យតាក់តែង) *អាស្រ័យ នូវសង្ខតធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូបក្តី អាស្រ័យ នូវសង្ខតក្ខន្ធ ១ ក្នុងខណៈនៃបដិសន្ធិ វត្ថុ អាស្រ័យ នូវពួកខន្ធ ពួកខន្ធ អាស្រ័យ នូវវត្ថុ មហាភូត ១ . . . ចិត្តសមុដ្ឋានរូប កដត្តារូប និងឧបាទារូប អាស្រ័យ នូវពួកមហាភូត ។ សប្បច្ចយទុកៈ ដូចទុកៈនេះដែរ បណ្ឌិត គប្បីធ្វើ នូវទុកៈនេះ ឲ្យដូច សប្បច្ចយទុកៈចុះ មិនមានការធ្វើឲ្យផ្សេងគ្នាទេ ។*

ចប់ សង្ខតទុកៈ ។

# សនិទស្សនទុកៈ

## បដិច្ចវារៈ

[១៨៥] *អនិទស្សនធម៌* (ធម៌ ដែលមិនប្រកបដោយការឃើញ) *អាស្រ័យ នូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្សនៈក្តី អាស្រ័យ នូវអនិទស្សនក្ខន្ធ ១ នូវខន្ធ ២ . . . ក្នុងខណៈ នៃបដិសន្ធិ ខន្ធ ៣ ក្តី កដត្តារូប ជាអនិទស្សនៈក្តី អាស្រ័យ នូវអនិទស្សនក្ខន្ធ ១*

ទ្វេ ខន្ធេ . . . ខន្ធេ បដិច្ច វត្ថុ វត្ថុំ បដិច្ច ខន្ធា ឯកំ មហាភូតំ . . . មហាភូតេ បដិច្ច អនិទស្សនំ ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ។ អនិទស្សនំ ធម្មំ បដិច្ច សនិទស្សនោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនិទស្សនេ ខន្ធេ បដិច្ច សនិទស្សនំ ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ មហាភូតេ បដិច្ច សនិទស្សនំ ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ។ អនិទស្សនំ ធម្មំ បដិច្ច សនិទស្សនោ ច អនិទស្សនោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា អនិទស្សនំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា សនិទស្សនញ្ច អនិទស្សនញ្ច ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . . បដិសន្ធិក្ខណេ មហាភូតេ បដិច្ច សនិទស្សនញ្ច អនិទស្សនញ្ច ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ។

[១៨៦] អនិទស្សនំ ធម្មំ បដិច្ច អនិទស្សនោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អនិទស្សនំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា ទ្វេ ខន្ធេ . . . បដិសន្ធិក្ខណេ វត្ថុំ បដិច្ច ខន្ធា ។

នូវខន្ធ ២ . . . វត្ថុ អាស្រ័យ នូវពួកខន្ធ ពួកខន្ធ អាស្រ័យ នូវវត្ថុ មហាភូត ១ . . . ចិត្តសមុដ្ឋានរូប ជាអនិទស្សនៈ កដត្តារូប និង ឧបាទារូប អាស្រ័យ នូវពួកមហាភូត ។ សនិទស្សនធម៌ (ធម៌ ដែលប្រកបដោយការឃើញ) អាស្រ័យ នូវអនិទស្សនធម៌ ទើបកើត ឡើង ព្រោះហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ អាស្រ័យ នូវពួកខន្ធ ជាអនិទស្សនៈ ក្នុងខណៈនៃបដិសន្ធិ ចិត្ត-សមុដ្ឋានរូប ជាសនិទស្សនៈ កដត្តារូប និងឧបាទារូប អាស្រ័យ នូវ ពួកមហាភូត ។ សនិទស្សនធម៌ក្តី អនិទស្សនធម៌ក្តី អាស្រ័យ នូវ អនិទស្សនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ និងអនិទស្សនៈក្តី អាស្រ័យ នូវ អនិទស្សនក្ខន្ធ ១ នូវខន្ធ ២ . . . ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ និងអនិទស្សនៈ កដត្តារូប និងឧបាទារូប អាស្រ័យ នូវពួកមហាភូត ។

[១៨៦] អនិទស្សនធម៌ អាស្រ័យ នូវអនិទស្សនធម៌ ទើប កើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ ខន្ធ ៣ អាស្រ័យ នូវអនិទស្ស-នក្ខន្ធ ១ នូវខន្ធ ២ . . . ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធ អាស្រ័យ នូវវត្ថុ ។

សនិទស្សនទុកេ បដិច្ចវារោ

[១៨៧] អនិទស្សនំ ធម្មំ បដិច្ច អនិទស្សនោ ធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា អនិទស្សនំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា អនិទស្សនំ ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . . ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ទ្វេ មហាភូតេ . . . មហាភូតេ បដិច្ច អនិទស្សនំ ចិត្ត-សមុដ្ឋានំ រូបំ ឧបាទារូបំ ។ អនិទស្សនំ ធម្មំ បដិច្ច សនិទស្សនោ ធម្មោ ឧប្បជ្ជតិ អធិបតិប្បច្ចយា អនិ-ទស្សនេ ខន្ធេ បដិច្ច សនិទស្សនំ ចិត្តសមុដ្ឋានំ រូបំ មហាភូតេ បដិច្ច សនិទស្សនំ ចិត្តសមុដ្ឋានំ រូបំ ឧបា-ទារូបំ ។ អនិទស្សនំ ធម្មំ បដិច្ច សនិទស្សនោ ច អនិទស្សនោ ច ធម្មា ឧប្បជ្ជន្តិ អធិបតិប្បច្ចយា អនិ-ទស្សនំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា សនិទស្សនញ្ច អនិទស្សនញ្ច ចិត្តសមុដ្ឋានំ រូបំ ទ្វេ ខន្ធេ . . . មហា-ភូតេ បដិច្ច សនិទស្សនញ្ច អនិទស្សនញ្ច ចិត្តស-មុដ្ឋានំ រូបំ ឧបាទារូបំ ។ សង្ខិត្តំ ។ សព្វេ កាតព្វា ។

[១៨៨] ហេតុយា តីណិ អារម្មណេ ឯកំ អធិ-បតិយា តីណិ អនន្តរេ ឯកំ សមនន្តរេ ឯកំ ស-ហជាតេ តីណិ អញ្ញមញ្ញេ ឯកំ និស្សយេ តីណិ

[១៨៧] អនិទស្សនធម៌ អាស្រ័យ នូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្សនៈក្តី អាស្រ័យ នូវអនិទស្សនក្ខន្ធ ១ នូវខន្ធ ២ . . . មហាភូត ៣ អាស្រ័យ នូវមហាភូត ១ នូវមហាភូត ២ . . . ចិត្តសមុដ្ឋានរូប ជាអនិទស្សនៈ និងឧបាទារូប អាស្រ័យ នូវពួកមហាភូត ។ សនិទស្សនធម៌ អាស្រ័យ នូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ អាស្រ័យ នូវពួកខន្ធ ជាអនិទស្សនៈ ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ និងឧបាទារូប អាស្រ័យ នូវពួកមហាភូត ។ សនិទស្សនធម៌ក្តី អនិទស្សនធម៌ក្តី អាស្រ័យ នូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះអធិបតិប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ និងអនិទស្សនៈក្តី អាស្រ័យ នូវអនិទស្សនក្ខន្ធ ១ នូវខន្ធ ២ . . . ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ និងអនិទស្សនៈ និងឧបាទារូប អាស្រ័យ នូវពួកមហាភូត ។ សេចក្តីបំប្រួញ ។ បណ្ឌិត គប្បីធ្វើ ឲ្យគ្រប់បច្ច័យទាំងអស់ចុះ ។

[១៨៨] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣

ឧបនិស្សយេ ឯកំ បុរេជាតេ ឯកំ អាសេវនេ ឯកំ កម្មេ តីណិ វិបាកេ តីណិ សព្វត្ថ តីណិ មគ្គេ តីណិ សម្បយុត្តេ ឯកំ វិប្បយុត្តេ តីណិ អត្ថិយា តីណិ នត្ថិយា ឯកំ វិគតេ ឯកំ អវិគតេ តីណិ ។ ឯវំ គណេតព្វំ ។

អនុលោមំ និដ្ឋិតំ ។

[១៨៩] អនិទស្សនំ ធម្មំ បដិច្ច អនិទស្សនោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ អនិទស្សនំ ឯកំ ខន្ធំ បដិច្ច តយោ ខន្ធា អនិទស្សនំ ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . . អហេតុកប្បដិសន្ធិក្ខណេ ខន្ធេ បដិច្ច វត្ថុ វត្ថុំ បដិច្ច ខន្ធា ឯកំ មហាភូតំ . . . មហាភូតេ បដិច្ច អនិទស្សនំ ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ ពាហិរំ . . . អាហារសមុដ្ឋានំ ឧតុសមុដ្ឋានំ អសញ្ញសត្តានំ . . . វិចិកិច្ឆាសហគតេ ឧទ្ធច្ចសហគតេ ខន្ធេ បដិច្ច វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។ អនិទស្សនំ ធម្មំ បដិច្ច សនិទស្សនោ ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា

ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ ក្នុងវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិ-ប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។ បណ្ឌិត គប្បីរាប់ យ៉ាងនេះចុះ ។

ចប់ អនុលោម ។

[១៨៩] អនិទស្សនធម៌ អាស្រ័យ នូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិ-ទស្សនៈក្តី អាស្រ័យ នូវអហេតុកក្ខន្ធ ១ ជាអនិទស្សនៈ នូវខន្ធ ២ . . . ក្នុងខណៈនៃអហេតុកប្បដិសន្ធិ វត្ថុ អាស្រ័យ នូវពួកខន្ធ ពួកខន្ធ អាស្រ័យ នូវវត្ថុ មហាភូត ១ . . . ចិត្តសមុដ្ឋានរូប ជាអនិទស្សនៈ កដត្តារូប និងឧបាទារូប អាស្រ័យ នូវពួកមហាភូត ពាហិរៈ . . . អាហារសមុដ្ឋាន ឧតុសមុដ្ឋាន របស់ពួកអសញ្ញសត្វ . . . មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ អាស្រ័យ នូវពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ។ សនិទស្សនធម៌ អាស្រ័យ នូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ

អហេតុកោ អនិទស្សនេ ខន្ធេ បដិច្ច សនិទស្សនំ ចិត្តសមុដ្ឋានំ រូបំ បដិសន្ធិក្ខណេ មហាភូតេ បដិច្ច សនិទស្សនំ ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទា-រូបំ ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . . អសញ្ញសត្តានំ មហាភូតេ បដិច្ច សនិទស្សនំ កដត្តារូបំ ឧបាទារូបំ ។ អនិទស្សនំ ធម្មំ បដិច្ច សនិទស្សនោ ច អនិទស្សនោ ច ធម្មា ឧប្បជ្ជន្តិ នហេតុប្បច្ចយា អហេតុកំ អនិទស្សនំ ឯកំ ខន្ធំ បដិច្ច សនិទស្សនញ្ច អនិទស្សនញ្ច ចិត្តសមុដ្ឋានំ រូបំ ទ្វេ ខន្ធេ . . . បដិសន្ធិក្ខណេ មហាភូតេ បដិច្ច . . . ពាហិរំ . . . អាហារសមុដ្ឋានំ . . . ឧតុសមុដ្ឋានំ . . . អសញ្ញសត្តានំ មហាភូតេ បដិច្ច សនិទស្សនញ្ច អនិទស្សនញ្ច កដត្តារូបំ ឧបាទារូបំ ។ ឯវំ សព្វេ កាតព្វា ។

[១៩០] នហេតុយា តីណិ នអារម្មណេ តីណិ នអធិបតិយា តីណិ នអនន្តរេ តីណិ នសមនន្តរេ តីណិ នអញ្ញមញ្ញេ តីណិ នឧបនិស្សយេ តីណិ នបុ-រេជាតេ តីណិ នបច្ឆាជាតេ តីណិ នអាសេវនេ តីណិ នកម្មេ តីណិ នវិបាកេ តីណិ នអាហារេ តីណិ

ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ អាស្រ័យ នូវពួកអហេតុកក្ខន្ធ ជាអនិទស្សនៈ ក្នុងខណៈនៃបដិសន្ធិ ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ កដត្តារូប និងឧបាទារូប អាស្រ័យ នូវពួកមហាភូត ពាហិរៈ . . . អាហារសមុដ្ឋាន . . . ឧតុសមុដ្ឋាន . . . កដត្តារូប ជាសនិទស្សនៈ និងឧបាទារូប អាស្រ័យ នូវពួកមហាភូត របស់ពួកអសញ្ញសត្វ ។ សនិទស្សនធម៌ក្តី អនិទស្សនធម៌ក្តី អាស្រ័យ នូវអនិទស្សនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ និងអនិទស្សនៈ អាស្រ័យ នូវអហេតុកក្ខន្ធ ១ ជាអនិទស្សនៈ នូវខន្ធ ២ . . . អាស្រ័យ នូវពួកមហាភូត ក្នុងខណៈនៃបដិសន្ធិ . . . ពាហិរៈ . . . អាហារសមុដ្ឋាន . . . ឧតុសមុដ្ឋាន . . . កដត្តារូប ជាសនិទស្សនៈ និងអនិទស្សនៈ និងឧបាទារូប អាស្រ័យ នូវពួកមហាភូត របស់ពួកអសញ្ញសត្វ ។ បច្ច័យទាំងអស់ បណ្ឌិត គប្បីធ្វើ យ៉ាងនេះចុះ ។

[១៩០] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងនអនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនសមនន្តរប្បច្ច័យ មានវារៈ ៣ ក្នុងនអញ្ញមញ្ញប្បច្ច័យ មានវារៈ ៣ ក្នុងនឧបនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងនបុរេជាតប្បច្ច័យ មានវារៈ ៣ ក្នុងនបច្ឆាជាតប្បច្ច័យ មានវារៈ ៣ ក្នុងនអាសេវនប្បច្ច័យ មានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ៣ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនអាហារប្បច្ច័យ មានវារៈ ៣

នឥន្ទ្រិយេ តីណិ នឈានេ តីណិ នមគ្គេ តីណិ នសម្បយុត្តេ តីណិ នវិប្បយុត្តេ តីណិ នោនត្ថិយា តីណិ នោវិគតេ តីណិ ។

បច្ចនីយំ និដ្ឋិតំ ។

[១៩១] ហេតុប្បច្ចយា នអារម្មណេ តីណិ . . . នអធិបតិយា តីណិ សព្វត្ថ តីណិ នកម្មេ ឯកំ នវិបាកេ តីណិ នសម្បយុត្តេ តីណិ នវិប្បយុត្តេ ឯកំ នោនត្ថិយា តីណិ នោវិគតេ តីណិ ។

អនុលោមប្បច្ចនីយំ និដ្ឋិតំ ។

[១៩២] នហេតុប្បច្ចយា អារម្មណេ ឯកំ . . . អនន្តរេ ឯកំ សមនន្តរេ ឯកំ សហជាតេ តីណិ អញ្ញមញ្ញេ ឯកំ និស្សយេ តីណិ ឧបនិស្សយេ ឯកំ បុរេជាតេ ឯកំ អាសេវនេ ឯកំ កម្មេ តីណិ សង្ខិត្តំ . . . ឈានេ តីណិ មគ្គេ ឯកំ សម្បយុត្តេ ឯកំ

ក្នុងនឥន្ទ្រិយប្បច្ច័យ មានវារៈ ៣ ក្នុងនឈានប្បច្ច័យ មានវារៈ ៣ ក្នុងនមគ្គប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ចប់ បច្ចនីយៈ ។

[១៩១] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ . . . ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ៣ ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិបាកប្បច្ច័យ មានវារៈ ៣ ក្នុងនសម្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ចប់ អនុលោមប្បច្ចនីយៈ ។

[១៩២] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ . . . ក្នុងអនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ៣ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ១ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៣ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ១ ក្នុងបុរេជាតប្បច្ច័យ មានវារៈ ១ ក្នុងអាសេវនប្បច្ច័យ មានវារៈ ១ ក្នុងកម្មប្បច្ច័យ មានវារៈ ៣ សេចក្តីបំប្រួញ . . . ក្នុងឈានប្បច្ច័យ មានវារៈ ៣ ក្នុងមគ្គប្បច្ច័យ មានវារៈ ១ ក្នុងសម្បយុត្តប្បច្ច័យ មានវារៈ ១

វិប្បយុត្តេ តីណិ អត្ថិយា តីណិ នត្ថិយា ឯកំ វិគតេ ឯកំ អវិគតេ តីណិ ។

បច្ចនីយានុលោមំ និដ្ឋិតំ ។

# បច្ចយវារោ

[១៩៣] អនិទស្សនំ ធម្មំ បច្ចយា អនិទស្សនោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនិទស្សនំ ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា អនិទស្សនំ ចិត្តសមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . . បដិសន្ធិក្ខណេ ខន្ធេ បច្ចយា វត្ថុ វត្ថុំ បច្ចយា ខន្ធា ឯកំ មហាភូតំ បច្ចយា . . . មហាភូតេ បច្ចយា អនិទស្សនំ ចិត្តសមុដ្ឋានំ រូបំ កដត្តារូបំ ឧបាទារូបំ វត្ថុំ បច្ចយា អនិទស្សនា ខន្ធា ។ ឥតរេបិ ទ្វេ បញ្ហា កាតព្វា ។

[១៩៤] អនិទស្សនំ ធម្មំ បច្ចយា អនិទស្សនោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា អនិទស្សនំ ឯកំ ខន្ធំ . . . ទ្វេ ខន្ធេ . . . បដិសន្ធិក្ខណេ វត្ថុំ បច្ចយា ខន្ធា ចក្ខាយតនំ បច្ចយា ចក្ខុវិញ្ញាណំ កាយាយតនំ បច្ចយា កាយវិញ្ញាណំ វត្ថុំ បច្ចយា អនិទស្សនា ខន្ធា ។ សង្ខិត្តំ ។

*ក្នុងវិប្បយុត្តប្បច្ច័យ មានវារៈ ៣ ក្នុងអត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនត្ថិប្បច្ច័យ មានវារៈ ១ ក្នុងវិគតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។*

ចប់ បច្ចនីយានុលោម ។

# បច្ចយវារៈ

[១៩៣] *អនិទស្សនធម៌ ពឹងផ្អែក នឹងអនិទស្សនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្សនៈក្តី ពឹងផ្អែក នឹងអនិទស្សនក្ខន្ធ ១ នឹងខន្ធ ២ . . . ក្នុងខណៈនៃបដិសន្ធិ វត្ថុ ពឹងផ្អែក នឹងពួកខន្ធ ពួកខន្ធ ពឹងផ្អែក នឹងវត្ថុ ពឹងផ្អែក នឹងមហាភូត ១ . . . ចិត្តសមុដ្ឋានរូប ជាអនិទស្សនៈ កដត្តារូប និងឧបាទារូប ពឹងផ្អែក នឹងពួកមហាភូត ពួកអនិទស្សនក្ខន្ធ ពឹងផ្អែក នឹងវត្ថុ ។ ឯប្រស្នា ២ ក្រៅនេះ បណ្ឌិត គប្បីធ្វើចុះ ។*

[១៩៤] *អនិទស្សនធម៌ ពឹងផ្អែក នឹងអនិទស្សនធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ គឺ នឹងអនិទស្សនក្ខន្ធ ១ . . . នឹងខន្ធ ២ . . . ក្នុងខណៈនៃបដិសន្ធិ ពួកខន្ធ ពឹងផ្អែក នឹងវត្ថុ ចក្ខុវិញ្ញាណ ពឹងផ្អែក នឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែក នឹងកាយាយតនៈ ពួកអនិទស្សនក្ខន្ធ ពឹងផ្អែក នឹងវត្ថុ ។ សេចក្តីបំប្រួញ ។*

[១៩៥] ហេតុយា តីណិ អារម្មណេ ឯកំ អធិ-
បតិយា តីណិ ។ បេ ។ អវិគតេ តីណិ ។

អនុលោមំ និដ្ឋិតំ ។

[១៩៦] អធិគស្សនំ ធម្មំ បច្ចយា អនិគស្សនោ
ធម្មោ ឧប្បជ្ជតិ នហេតុប្បច្ចយា អហេតុកំ អនិទស្សនំ
ឯកំ ខន្ធំ បច្ចយា តយោ ខន្ធា អនិទស្សនំ ចិត្ត-
សមុដ្ឋានញ្ច រូបំ ទ្វេ ខន្ធេ . . . អហេតុកប្បដិសន្ធិក្ខ-
ណេ . . . យាវ អសញ្ញសត្តា ចក្ខាយតនំ បច្ចយា
ចក្ខុវិញ្ញាណំ កាយាយតនំ បច្ចយា កាយវិញ្ញាណំ
វត្ថុំ បច្ចយា អហេតុកា អនិទស្សនា ខន្ធា វិចិកិច្ឆា-
សហគតេ ឧទ្ធច្ចសហគតេ ខន្ធេ ច វត្ថុញ្ច បច្ចយា
វិចិកិច្ឆាសហគតោ ឧទ្ធច្ចសហគតោ មោហោ ។
ឥតរេបិ ទ្វេ កាតព្វា ។ សង្ខិត្តំ ។

[១៩៧] នហេតុយា តីណិ នអារម្មណេ តីណិ
នោវិគតេ តីណិ ។

បច្ចនីយំ និដ្ឋិតំ ។

[១៩៨] ហេតុប្បច្ចយា នអារម្មណេ តីណិ . . .

[១៩៥] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ។ បេ ។ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ចប់ អនុលោម ។

[១៩៦] អនិទស្សនធម៌ ពឹងផ្អែក នឹងអនិទស្សនធម៌ ទើបកើតឡើង ព្រោះនហេតុប្បច្ច័យ គឺ ខន្ធ ៣ ក្តី ចិត្តសមុដ្ឋានរូប ជាអនិទស្សនៈក្តី ពឹងផ្អែក នឹងអហេតុកក្ខន្ធ ១ ជាអនិទស្សនៈ នឹងខន្ធ ២ . . . ក្នុងខណៈនៃអហេតុកប្បដិសន្ធិ . . . រហូតដល់ពួកអសញ្ញសត្វ ចក្ខុវិញ្ញាណ ពឹងផ្អែក នឹងចក្ខាយតនៈ កាយវិញ្ញាណ ពឹងផ្អែក នឹងកាយាយតនៈ ពួកអហេតុកក្ខន្ធ ជាអនិទស្សនៈ ពឹងផ្អែក នឹងវត្ថុ មោហៈ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈ ពឹងផ្អែក នឹងពួកខន្ធ ដែលប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈផង វត្ថុផង ។ ឯប្រស្នាទាំង ២ ក្រៅនេះ បណ្ឌិត គប្បីធ្វើចុះ ។ សេចក្តីបំប្រួញ ។

[១៩៧] ក្នុងនហេតុប្បច្ច័យ មានវារៈ ៣ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ចប់ បច្ចនីយៈ ។

[១៩៨] ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៣ ព្រោះហេតុប្បច្ច័យ . . .

នកម្មេ ឯកំ នវិប្បយុត្តេ ឯកំ នោនត្ថិយា តីណិ នោវិគតេ តីណិ ។

អនុលោមប្បច្ចនីយំ និដ្ឋិតំ ។

[១៩៩] នហេតុប្បច្ចយា អារម្មណេ ឯកំ . . . មគ្គេ ឯកំ អវិគតេ តីណិ ។

បច្ចនីយានុលោមំ និដ្ឋិតំ ។

និស្សយវារោបិ ឯវំ កាតព្វោ ។

# សំសដ្ឋវារោ

[២០០] អនិទស្សនំ ធម្មំ សំសដ្ឋោ អនិទស្សនោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អនិទស្សនំ ឯកំ ខន្ធំ សំសដ្ឋា តយោ ខន្ធា ទ្វេ ខន្ធេ . . . បដិសន្ធិ ។

[២០១] អនិទស្សនំ ធម្មំ សំសដ្ឋោ អនិទស្សនោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា ។ ឯវំ សព្វំ សប្បច្ចយគណនាបិ សទ្ធឹ កាតព្វំ ។

សម្បយុត្តវារោបិ សំសដ្ឋវារសទិសោ ។

ក្នុងនកម្មប្បច្ច័យ មានវារៈ ១ ក្នុងនវិប្បយុត្តប្បច្ច័យ មានវារៈ ១ ក្នុងនោនត្ថិប្បច្ច័យ មានវារៈ ៣ ក្នុងនោវិគតប្បច្ច័យ មានវារៈ ៣ ។

ចប់ អនុលោមបច្ចនីយៈ ។

[១៩៩] ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ព្រោះនហេតុប្បច្ច័យ ... ក្នុងមគ្គប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ចប់ បច្ចនីយានុលោម ។

ឯនិស្សយវារៈ បណ្ឌិត គប្បីធ្វើ យ៉ាងនេះដែរ ។

# សំសដ្ឋវារៈ

[២០០] អនិទស្សនធម៌ ប្រឡំ នឹងអនិទស្សនធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ខន្ធ ៣ ប្រឡំ នឹងខន្ធ ១ ជាអនិទស្សនៈ នឹងខន្ធ ២... មានបដិសន្ធិដែរ ។

[២០១] អនិទស្សនធម៌ ប្រឡំ នឹងអនិស្សនធម៌ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ បទទាំងអស់ បណ្ឌិត គប្បីធ្វើមួយអន្លើ ដោយការរាប់នូវសប្បច្ចយៈទាំងឡាយ យ៉ាងនេះចុះ ។

សម្បយុត្តវារៈ ដូចសំសដ្ឋវារៈដែរ ។

# បញ្ហាវារោ

[២០២] អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អនិទស្សនា ហេតូ សម្បយុត្តកានំ ខន្ធានំ អនិទស្សនានំ ចិត្ត-សមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ បដិសន្ធិក្ខណេ . . . ។ អនិទស្សនោ ធម្មោ សនិ-ទស្សនស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អនិ-ទស្សនា ហេតូ សនិទស្សនានំ ចិត្តសមុដ្ឋានានំ រូបា-នំ ហេតុប្បច្ចយេន បច្ចយោ បដិសន្ធិក្ខណេ . . . ។ អនិទស្សនោ ធម្មោ សនិទស្សនស្ស ច អនិទស្ស-នស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អនិ-ទស្សនា ហេតូ សម្បយុត្តកានំ ខន្ធានំ សនិទស្ស-នានញ្ច អនិទស្សនានញ្ច ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ បដិសន្ធិក្ខណេ . . . ។

[២០៣] សនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ សនិទស្សនំ រូបំ អនិច្ចតោ . . . ទោមនស្សំ ឧប្បជ្ជតិ

# បញ្ហាវារៈ

[២០២] អនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយហេតុប្បច្ច័យ គឺ ពួកអនិទស្សនហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនៈផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ . . . ។ អនិទស្សនធម៌ ជាបច្ច័យ នៃសនិទស្សនធម៌ ដោយហេតុប្បច្ច័យ គឺ ពួកអនិទស្សនហេតុ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ . . . ។ អនិទស្សនធម៌ ជាបច្ច័យ នៃសនិទស្សនធម៌ផង នៃអនិទស្សនធម៌ផង ដោយហេតុប្បច្ច័យ គឺ ពួកអនិទស្សនហេតុ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ និងជាអនិទស្សនៈផង ដោយហេតុប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ . . . ។

[២០៣] សនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយអារម្មណប្បច្ច័យ គឺ នូវសនិទស្សនរូប ថាមិនទៀង . . . ទោមនស្ស កើតឡើង

១៦៩



ទិព្វេន ចក្ខុនា . . . រូបាយតនំ ចក្ខុវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ សនិទស្សនា ខន្ធា ឥទ្ធិវិធញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។ អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទានំ . . . សីលំ . . . ឧបោសថកម្មំ . . . តំ បច្ចវេក្ខតិ បុព្វេ សុចិណ្ណានិ បច្ចវេក្ខតិ ឈានា វុដ្ឋហិត្វា ឈានំ បច្ចវេក្ខតិ អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ បច្ចវេក្ខន្តិ ផលំ បច្ចវេក្ខន្តិ និព្វានំ បច្ចវេក្ខន្តិ និព្វានំ គោត្រភុស្ស វោទានស្ស មគ្គស្ស ផលស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ អរិយា បហីនេ កិលេសេ បច្ចវេក្ខន្តិ វិក្ខម្ភិតេ កិលេសេ . . . បុព្វេ . . . ចក្ខុំ . . . កាយំ សទ្ទេ វត្ថុំ . . . អនិទស្សនេ ខន្ធេ អនិច្ចតោ . . . ទោមនស្សំ ឧប្បជ្ជតិ ទិព្វាយ សោតធាតុយា សទ្ទំ សុណាតិ ចេតោបរិយញ្ញាណេន អនិទស្សនចិត្តសមង្គិស្ស ចិត្តំ ជានាតិ អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនស្ស អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនស្ស សទ្ទាយតនំ

ដោយទិព្វចក្ខុ . . . រូបាយតនៈ ជាបច្ច័យ នៃចក្ខុវិញ្ញាណ ដោយអារម្មណប្បច្ច័យ ពួកសនិទស្សនក្ខន្ធ ជាបច្ច័យ នៃការពិចារណា នូវឥទ្ធិវិធញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។ អនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយអារម្មណប្បច្ច័យ គឺ ទាន . . . សីល . . . ឧបោសថកម្ម . . . ពិចារណា នូវកុសលនោះ ពិចារណា នូវពួកកុសល ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន ចេញអំពីឈាន ពិចារណា នូវឈាន ពួកព្រះអរិយៈ ចេញអំពីមគ្គ ពិចារណា នូវមគ្គ ពិចារណា នូវផល ពិចារណា នូវព្រះនិព្វាន ឯព្រះនិព្វាន ជាបច្ច័យ នៃការពិចារណា នូវគោត្រភូ វោទានៈ មគ្គ និងផល ដោយអារម្មណប្បច្ច័យ ពួកព្រះអរិយៈពិចារណា នូវពួកកិលេស ដែលលះបង់ហើយ នូវពួកកិលេស ដែលសង្កត់សង្កិនហើយ . . . . ក្នុងកាលមុន . . . នូវចក្ខុ . . . នូវកាយ នូវពួកសំឡេង នូវវត្ថុ . . . នូវពួកអនិទស្សនក្ខន្ធ ថាមិនទៀង . . . ទោមនស្ស កើតឡើង ឮ នូវសំឡេង ដោយទិព្វសោតធាតុ ដឹងនូវចិត្ត របស់បុគ្គល ដែលប្រកបដោយអនិទស្សនចិត្ត ដោយចេតោបរិយញ្ញាណ អាកាសានញ្ចាយតនៈ (ជាបច្ច័យ) នៃវិញ្ញាណញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ (ជាបច្ច័យ) នៃនេវសញ្ញានាសញ្ញាយតនៈ សទ្ទាយតនៈ

សោតវិញ្ញាណស្ស ឃានវិញ្ញាណស្ស ជិវ្ហាវិញ្ញាណស្ស កាយវិញ្ញាណស្ស អនិទស្សនា ខន្ធា ឥទ្ធិវិធញាណស្ស ចេតោបរិយញ្ញា-ណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្ម-បគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។

[២០៤] សនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ អនិទស្សនំ រូបំ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។ អនិទស្ស-នោ ធម្មោ អនិទស្សនស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អារម្មណាធិបតិ សហជាតាធិបតិ ។ អារម្ម-ណាធិបតិ ទានំ ទត្វា សីលំ . . . ឧបោសថកម្មំ . . . តំ គរុំ កត្វា . . . បុព្វេ សុចិណ្ណានិ . . . ឈានា វុដ្ឋហិត្វា . . . អរិយា មគ្គា វុដ្ឋហិត្វា មគ្គំ គរុំ កត្វា . . . ផលំ គរុំ កត្វា . . . និព្វានំ គោត្រភុស្ស វោទានស្ស មគ្គស្ស ផលស្ស អធិបតិប្បច្ចយេន បច្ចយោ ចក្ខុំ . . . វត្ថុំ . . . អនិទស្សនេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។

(ជាបច្ច័យ) នៃសោតវិញ្ញាណ ផោដ្ឋព្វាយតនៈ (ជាបច្ច័យ) នៃកាយ-វិញ្ញាណ ពួកអនិទស្សនក្ខន្ធ ជាបច្ច័យ នៃការពិចារណា នូវឥទ្ធិវិ-ធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុ-បគញ្ញាណ និងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

[២០៤] សនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ គឺ បុគ្គល ធ្វើ នូវអនិ-ទស្សនរូប ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ធ្វើ នូវរូបនោះ ឲ្យជាទីគោរព ហើយកើតឡើង ទិដ្ឋិ កើតឡើង ។ អនិទស្ស-នធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយអធិបតិប្បច្ច័យ បានដល់អារម្មណាធិបតិ និងសហជាតាធិបតិ ។ អារម្មណាធិបតិ គឺ បុគ្គលឲ្យទាន សីល . . . ឧបោសថកម្ម . . . ធ្វើ នូវកម្មនោះ ឲ្យជាទីគោរព . . . នូវពួកកុសល ដែលធ្លាប់សន្សំហើយ ក្នុងកាលមុន . . . ចេញអំពីឈាន . . . ពួកព្រះអរិយៈ ចេញអំពីមគ្គ ធ្វើ នូវមគ្គឲ្យជាទីគោរព . . . ធ្វើ នូវផល ឲ្យជាទីគោរព . . . ព្រះនិព្វានជាបច្ច័យ នៃគោត្រភូ វោទានៈ មគ្គ និងផល ដោយអធិបតិប្ប-ច្ច័យ នូវចក្ខុ . . . នូវវត្ថុ . . . បុគ្គល ធ្វើ នូវពួកអនិ-ទស្សនក្ខន្ធ ឲ្យជាទីគោរព ហើយត្រេកអរ រីករាយ រាគៈ ធ្វើនូវខន្ធនោះ ឲ្យជាទីគោរព ហើយកើតឡើង ទិដ្ឋិ កើតឡើង ។

សហជាតាធិបតិ អនិទស្សនាធិបតិ សម្បយុត្តកានំ ខន្ធានំ អនិទស្សនានំ ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។ អនិទស្សនោ ធម្មោ សនិទស្សនស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ សហជាតាធិបតិ អនិទស្សនាធិបតិ សនិទស្សនានំ ចិត្តសមុដ្ឋានានំ រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។ អនិទស្សនោ ធម្មោ សនិទស្សនស្ស ច អនិទស្សនស្ស ច ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ សហជាតា-ធិបតិ អនិទស្សនាធិបតិ សម្បយុត្តកានំ ខន្ធានំ សនិទស្សនានញ្ច អនិទស្សនានញ្ច ចិត្តសមុដ្ឋានានញ្ច រូបានំ អធិបតិប្បច្ចយេន បច្ចយោ ។

[២០៥] អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ បុរិមា បុរិមា អនិ-ទស្សនា ខន្ធា បច្ឆិមានំ បច្ឆិមានំ អនិទស្សនានំ ខន្ធានំ អនន្តរប្បច្ចយេន បច្ចយោ អនុលោមំ គោត្រភុស្ស គោត្រភុ មគ្គស្ស នេវសញ្ញានាសញ្ញាយតនំ ផលស-មាបត្តិយា អនន្តរប្បច្ចយេន បច្ចយោ ។

[២០៦] អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស

សហជាតាធិបតិ គឺ អធិបតិធម៌ ជាអនិទស្សនៈ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាអនិទស្សនៈផង ដោយអធិបតិប្បច្ច័យ ។ អនិទស្សនធម៌ ជាបច្ច័យ នៃសនិទស្សនធម៌ ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺ អធិបតិធម៌ ជាអនិទស្សនៈ ជាបច្ច័យ នៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ ដោយអធិបតិប្បច្ច័យ ។ អនិទស្សនធម៌ ជាបច្ច័យ នៃសនិទស្សនធម៌ផង នៃអនិទស្សនធម៌ផង ដោយអធិបតិប្បច្ច័យ បានដល់សហជាតាធិបតិ គឺ អធិបតិធម៌ ជាអនិទស្សនៈ ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្តសមុដ្ឋានរូប ជាសនិទស្សនៈ និងជាអនិទស្សនៈផង ដោយអធិបតិប្បច្ច័យ ។

[២០៥] អនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយអនន្តរប្បច្ច័យ ពួកអនិទស្សនក្ខន្ធ មុន ៗ ជាបច្ច័យ នៃពួកអនិទស្សនក្ខន្ធ ក្រោយ ៗ ដោយអនន្តរប្បច្ច័យ អនុលោម (ជាបច្ច័យ) នៃគោត្រភូ គោត្រភូ (ជាបច្ច័យ) នៃមគ្គ នេវសញ្ញានាសញ្ញាយតនៈ ជាបច្ច័យ នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។

[២០៦] អនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌

សមនន្តរប្បច្ចយេន បច្ចយោ ។ សហជាតប្បច្ចយេន បច្ចយោ តីណិ ។ អញ្ញមញ្ញប្បច្ចយេន បច្ចយោ ឯកំ ។ និស្សយប្បច្ចយេន បច្ចយោ តីណិ ។

[២០៧] សនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ បកតូបនិស្សយោ ។ បេ ។ បកតូបនិស្សយោ វណ្ណសម្បទំ បត្ថយមានោ ទានំ . . . សីលំ . . . ឧបោសថកម្មំ ករោតិ វណ្ណសម្បទា សទ្ធាយ ។ បេ ។ បត្ថនាយ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស មគ្គស្ស ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។ អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ អារម្មណូបនិស្សយោ អនន្តរូបនិស្សយោ បកតូបនិស្សយោ ។ បេ ។ បកតូបនិស្សយោ សទ្ធំ ឧបនិស្សាយ ទានំ ទេតិ ។ បេ ។ សមាបត្តឹ ឧប្បាទេតិ មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ សីលំ . . . ។ បេ ។ សេនាសនំ ឧបនិស្សាយ ទានំ ទេតិ ។ បេ ។ សង្ឃំ ភិន្ទតិ សទ្ធា ។ បេ ។ សេនាសនំ សទ្ធាយ ។ បេ ។ ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។

ដោយសមនន្តរប្បច្ច័យ ។ ជាបច្ច័យ ដោយសហជាតប្បច្ច័យ គឺ មាន វារៈ ៣ ។ ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ គឺ មានវារៈ ១ ។ ជា បច្ច័យ ដោយនិស្សយប្បច្ច័យ គឺ មានវារៈ ៣ ។

[២០៧] សនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយ ឧបនិស្សយប្បច្ច័យ បានដល់អារម្មណូបនិស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯបកតូបនិស្ស័យ គឺ បុគ្គល ប្រាថ្នា នូវវណ្ណសម្បទា ទាន . . . សីល . . . ធ្វើឧបោសថកម្ម វណ្ណសម្បទា ជាបច្ច័យ នៃសទ្ធា ។ បេ ។ នៃសេចក្តីប្រាថ្នា កាយិកសុខ កាយិកទុក្ខ មគ្គ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។ អនិទស្សនធម៌ ជា បច្ច័យ នៃអនិទស្សនធម៌ ដោយឧបនិស្សយប្បច្ច័យ បានដល់អារម្ម-ណូបនិស្ស័យ អនន្តរូបនិស្ស័យ និងបកតូបនិស្ស័យ ។ បេ ។ ឯបក-តូបនិស្ស័យ គឺ បុគ្គល អាស្រ័យ នូវសទ្ធា ហើយឲ្យទាន ។ បេ ។ ញុំាងសមាបត្តិ ឲ្យកើតឡើង ដំឡើងមានះ ប្រកាន់ទិដ្ឋិ នូវសីល . . . ។ បេ ។ អាស្រ័យ នូវសេនាសនៈ ហើយឲ្យទាន ។ បេ ។ បំបែក សង្ឃ សទ្ធា ។ បេ ។ សេនាសនៈ ជាបច្ច័យ នៃសទ្ធា ។ បេ ។ នៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

សនិទស្សនទុកេ បញ្ហាវារោ

[២០៨] សនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ សនិទស្សនំ រូបំ អនិច្ចតោ . . . ទោមនស្សំ ឧប្បជ្ជតិ ទិព្វេន ចក្ខុនា រូបំ បស្សតិ រូបាយតនំ ចក្ខុវិញ្ញាណស្ស បុរេជាតប្បច្ចយេន បច្ចយោ ។ អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ អារម្មណបុរេជាតំ វត្ថុបុរេជាតំ ។ អារម្មណបុរេជាតំ ចក្ខុំ . . . វត្ថុំ អនិច្ចតោ . . . ទោមនស្សំ ឧប្បជ្ជតិ ទិព្វាយ សោតធាតុយា សទ្ទំ សុណាតិ សទ្ទាយតនំ សោតវិញ្ញាណស្ស ផោដ្ឋព្វាយតនំ កាយវិញ្ញាណស្ស បុរេជាតប្បច្ចយេន បច្ចយោ ។ វត្ថុបុរេជាតំ ចក្ខាយតនំ ចក្ខុវិញ្ញាណស្ស កាយាយតនំ កាយវិញ្ញាណស្ស វត្ថុ អនិទស្សនានំ ខន្ធានំ បុរេជាតប្បច្ចយេន បច្ចយោ ។ សនិទស្សនោ ច អនិទស្សនោ ច ធម្មា អនិទស្សនស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ អារម្មណបុរេជាតំ វត្ថុបុរេជាតំ រូបាយតនញ្ច វត្ថុ ច អនិទស្សនានំ ខន្ធានំ បុរេជាតប្បច្ចយេន បច្ចយោ រូបាយតនញ្ច ចក្ខាយតនញ្ច ចក្ខុវិញ្ញាណស្ស បុរេជាតប្បច្ចយេន បច្ចយោ ។

សនិទស្សនទុកៈ បញ្ហាវារៈ

[២០៨] *សនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយបុរេជាតប្បច្ច័យ គឺ* (*បុគ្គល*) *នូវសនិទស្សនរូប ថាមិនទៀង . . . ទោមនស្ស កើតឡើង បុគ្គល ឃើញ នូវរូប ដោយទិព្វចក្ខុ រូបាយតនៈ ជាបច្ច័យ នៃចក្ខុវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ អនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត ។ អារម្មណបុរេជាត គឺ នូវចក្ខុ . . . នូវវត្ថុ ថាមិនទៀង . . . ទោមនស្ស កើតឡើង ឮ នូវសំឡេង ដោយទិព្វសោតធាតុ សទ្ទាយតនៈ* (*ជាបច្ច័យ*) *នៃសោតវិញ្ញាណ ផោដ្ឋព្វាយតនៈ ជាបច្ច័យ នៃកាយវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។ ឯវត្ថុបុរេជាត គឺ ចក្ខាយតនៈ* (*ជាបច្ច័យ*) *នៃចក្ខុវិញ្ញាណ កាយាយតនៈ* (*ជាបច្ច័យ*) *នៃកាយវិញ្ញាណ វត្ថុ ជាបច្ច័យ នៃពួកអនិទស្សនក្ខន្ធ ដោយបុរេជាតប្បច្ច័យ ។ សនិទស្សនធម៌ក្តី អនិទស្សនធម៌ក្តី ជាបច្ច័យ នៃអនិទស្សនធម៌ ដោយបុរេជាតប្បច្ច័យ បានដល់អារម្មណបុរេជាត និងវត្ថុបុរេជាត គឺ រូបាយតនៈក្តី វត្ថុក្តី ជាបច្ច័យ នៃពួកអនិទស្សនក្ខន្ធ ដោយបុរេជាតប្បច្ច័យ រូបាយតនៈក្តី ចក្ខាយតនៈក្តី ជាបច្ច័យ នៃចក្ខុវិញ្ញាណ ដោយបុរេជាតប្បច្ច័យ ។*

[២០៩] អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ បច្ឆាជាតា អនិទស្សនា ខន្ធា បុរេជាតស្ស ឥមស្ស អនិទស្ស-នស្ស កាយស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ ។ អនិទស្សនោ ធម្មោ សនិទស្សនស្ស ធម្មស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ បច្ឆាជាតា អនិទស្សនា ខន្ធា បុរេជាតស្ស ឥមស្ស សនិទស្សនស្ស កាយស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ ។ អនិទស្សនោ ធម្មោ សនិទស្សនស្ស ច អនិទស្សនស្ស ច ធម្មស្ស បច្ឆា-ជាតប្បច្ចយេន បច្ចយោ បច្ឆាជាតា អនិទស្សនា ខន្ធា បុរេជាតស្ស ឥមស្ស សនិទស្សនស្ស ច អនិទស្ស-នស្ស ច កាយស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ ។

[២១០] អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស អាសេវនប្បច្ចយេន បច្ចយោ បុរិមា . . . ។

[២១១] អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានា-ខណិកា ។ សហជាតា អនិទស្សនា ចេតនា សម្ប-យុត្តកានំ ខន្ធានំ អនិទស្សនានញ្ច ចិត្តសមុដ្ឋានានំ រូបានំ កម្មប្បច្ចយេន បច្ចយោ ។ នានាខណិកា

[២០៩] អនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់បច្ឆាជាត គឺ ពួកអនិទស្សនក្ខន្ធ ជាបច្ច័យ នៃអនិទស្សនកាយ នេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ អនិទស្សនធម៌ ជាបច្ច័យ នៃសនិទស្សនធម៌ ដោយបច្ឆាជាតប្បច្ច័យ បានដល់បច្ឆាជាត គឺ ពួកអនិទស្សនក្ខន្ធ ជាបច្ច័យ នៃសនិទស្សន-កាយនេះ ដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។ អនិទស្សនធម៌ ជាបច្ច័យ នៃសនិទស្សនធម៌ផង នៃអនិទស្សនធម៌ផង ដោយបច្ឆាជា-តប្បច្ច័យ បានដល់បច្ឆាជាត គឺ ពួកអនិទស្សនក្ខន្ធ ជាបច្ច័យ នៃសនិទស្សនកាយ និងអនិទស្សនកាយនេះ ដែលកើតមុន ដោយបច្ឆា-ជាតប្បច្ច័យ ។

[២១០] អនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយអាសេវនប្បច្ច័យ គឺ មុន ... ។

[២១១] អនិទស្សនធម៌ ជាបច្ច័យ នៃអនិទស្សនធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ ។ សហជាត គឺ អនិទស្សនចេតនា ជាបច្ច័យ នៃពួកសម្បយុត្តកក្ខន្ធផង នៃពួកចិត្ត-សមុដ្ឋានរូប ជាអនិទស្សនៈផង ដោយកម្មប្បច្ច័យ ។ ឯនានាខណិកៈ

អនិទស្សនា ចេតនា វិបាកានំ អនិទស្សនានំ ខន្ធានំ អនិទស្សនានញ្ច កដត្តារូបានំ កម្មប្បច្ចយេន បច្ច-យោ ។ អនិទស្សនោ ធម្មោ សនិទស្សនស្ស ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា ។ វិត្ថារេតព្វំ ។ អនិទស្សនោ ធម្មោ សនិទស្សនស្ស ច អនិទស្សនស្ស ច ធម្មស្ស កម្មប្បច្ចយេន បច្ចយោ សហជាតា នានាខណិកា ។ វិត្ថារេតព្វំ ។

[២១២] អនិទស្សនោ ធម្មោ អនិទស្សនស្ស ធម្មស្ស វិបាកប្បច្ចយេន បច្ចយោ តីណិ ។ . . . អាហារប្បច្ចយេន បច្ចយោ តីណិ តីសុបិ កពឡី-ការោ អាហារោ កាតព្វោ ។ . . . ឥន្ទ្រិយប្បច្ច-យេន បច្ចយោ តីណិ តីសុបិ រូបជីវិតិន្ទ្រិយំ ។ . . . ឈានប្បច្ចយេន បច្ចយោ តីណិ ។ . . . មគ្គប្បច្ច-យេន បច្ចយោ តីណិ ។ . . . សម្បយុត្តប្បច្ចយេន បច្ចយោ ឯកំ ។

គឺ អនិទស្សនចេតនា ជាបច្ច័យ នៃពួកវិបាកក្ខន្ធ ជាអនិទស្សនៈផង នៃពួកកដត្តារូប ជាអនិទស្សនៈផង ដោយកម្មប្បច្ច័យ ។ អនិទស្សនធម៌ ជាបច្ច័យ នៃសនិទស្សនធម៌ ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ ។ បណ្ឌិត គប្បីឲ្យពិស្តារចុះ ។ អនិទស្សនធម៌ ជាបច្ច័យ នៃសនិទស្សនធម៌ផង នៃអនិទស្សនធម៌ផង ដោយកម្មប្បច្ច័យ បានដល់សហជាត និងនានាខណិកៈ ។ បណ្ឌិត គប្បីឲ្យពិស្តារចុះ ។

